ជំពូកទី ២

# ជំងឺដែលគេច្រើនតែយល់ច្រឡំ

## តើមូលហេតុអ្វីដែលបណ្ដាលឲ្យមានជំងឺ?

មនុស្សពីប្រទេសផ្សេងៗ ឬពីមជ្ឈដ្ឋានផ្សេងៗ តែងតែមានការយល់ឃើញប្លែកៗពីគ្នាអំពីមូលហេតុដែលនាំឲ្យមានជំងឺ។ *កុមារម្នាក់មានជំងឺរាក។ តើបណ្ដាលមកពីអ្វី?*



**ប្រជាជននៅតាមភូមិ** អាចនិយាយថា មកពីឪពុកម្ដាយរបស់វាបានធ្វើអ្វីខុស ឬប្រហែលជាបានធ្វើឲ្យព្រះ ឬអារក្សអ្នកតាខឹងសម្បាអ្វីមួយហើយ។

**វេជ្ជបណ្ឌិត** អាចនិយាយថា ព្រោះកុមារនោះមានការបង្ករោគ។

**មន្ត្រីសុខភាពសាធារណៈ** អាចនិយាយថាមកពីអ្នកភូមិគ្មានប្រព័ន្ធទឹកស្អាត ឬគ្មានបង្គន់អនាម័យប្រើប្រាស់។

**ភ្នាក់ងារអភិវឌ្ឍន៍សហគមន៍** អាចនិយាយថា ការរស់នៅគ្មានអនាម័យដែលធ្វើឲ្យកុមារកើតជំងឺរាកជាញឹកញាប់នោះ បណ្ដាលមកពីការខ្វះយុត្តិធម៌ក្នុងការបែងចែកដីធ្លី និងធនធានផ្សេងៗ។

**គ្រូបង្រៀន** អាចទម្លាក់កំហុសទៅលើកង្វះខាតការអប់រំ។

មនុស្សមានការយល់ឃើញអំពីមូលហេតុនៃជំងឺទៅតាមបទពិសោធន៍ និងទស្សនៈរបស់គេរៀងៗខ្លួន។ ដូច្នេះ តើការយល់ឃើញរបស់អ្នកណា ជាការត្រឹមត្រូវ? ការយល់ឃើញរបស់មនុស្សគ្រប់រូប អាចសុទ្ធតែត្រឹមត្រូវ ឬត្រឹមត្រូវមួយផ្នែក ព្រោះ៖

**ជាទូទៅ ការមានជំងឺអាចបណ្ដាលមកពីមូលហេតុជាច្រើនយ៉ាងរួមបញ្ចូលគ្នា។**



*"ហេតុអ្វីវាកើតឡើងលើកូនខ្ញុំទៅវិញ?"*

ហេតុផលនីមួយៗដែលបានលើកឡើងខាងលើ អាចជាផ្នែកមួយនៃមូលហេតុដែលបណ្ដាលឲ្យកុមារម្នាក់កើតជំងឺរាកបាន។

ដើម្បីបង្ការនិងព្យាបាលជំងឺដោយជោគជ័យ ការយល់ដឹងយ៉ាងច្បាស់ អំពីជំងឺដែលកើតមានជាញឹកញាប់នៅក្នុងតំបន់របស់អ្នក និងអំពីបញ្ហាទាំងអស់ដែលបណ្ដាលឲ្យកើតជំងឺទាំងនោះ គឺជាការសំខាន់ណាស់។

នៅក្នុងសៀវភៅនេះ នឹងមានការពិភាក្សាអំពីជំងឺផ្សេងៗ ទៅតាមប្រព័ន្ធ និងវិធីព្យាបាលទំនើបឬតាមបែបវិទ្យាសាស្ត្រ។

**ដើម្បីប្រើសៀវភៅនេះឲ្យមានប្រយោជន៍ និងប្រើប្រាស់ថ្នាំពេទ្យឲ្យមានសុវត្ថិភាព អ្នកចាំបាច់ត្រូវមានការយល់ដឹងខ្លះៗ អំពីជំងឺផ្សេងៗ និងមូលហេតុរបស់វា តាមវិទ្យាសាស្ត្រវេជ្ជសាស្ត្រ។** ការអានជំពូកនេះ នឹងអាចជួយអ្នកបាន។

# ប្រភេទផ្សេងៗនៃជំងឺ និងមូលហេតុរបស់វា

នៅពេលគិតអំពីវិធីការពារ ឬព្យាបាលជំងឺផ្សេងៗ អ្នកត្រូវបែងចែកជំងឺទាំងនោះជា២ក្រុមគឺ ៖ ជំងឺឆ្លង និងជំងឺមិនឆ្លង។

១. **ជំងឺឆ្លង ៖** គឺជាជំងឺដែលអាចឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត។ យើងត្រូវតែការពារអ្នកដែលមានសុខភាពល្អ ពីអ្នកដែលមានជំងឺទាំងនេះ។

២. **ជំងឺមិនឆ្លង ៖** ជាជំងឺដែលមិនឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតទេ។ ជំងឺនេះមានមូលហេតុផ្សេងៗជាច្រើន។ ដូច្នេះ វាជាការសំខាន់ណាស់ ដែលត្រូវដឹងថា ជំងឺណាជាជំងឺឆ្លង និងជំងឺណាជាជំងឺមិនឆ្លង។

## ជំងឺមិនឆ្លង

ជំងឺមិនឆ្លង មានមូលហេតុច្រើនយ៉ាងផ្សេងៗគ្នា។ ប៉ុន្តែ ជំងឺនេះមិនបណ្តាលមកពីមេរោគ បាក់តេរី ឬភាវរស់ផ្សេងៗទៀត ដែលវាយប្រហាររាងកាយរបស់មនុស្សឡើយ។ ជំងឺទាំងនោះមិនឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតទេ។ ជាការសំខាន់ អ្នកត្រូវដឹងថា *ថ្នាំអង់ទីប៊ីយ៉ូទិក* ឬថ្នាំប្រឆាំងមេរោគ (ទំ.៥៥) ពុំអាចព្យាបាលជំងឺមិនឆ្លងនេះឲ្យជាបានទេ។

**ថ្នាំអង់ទីប៊ីយ៉ូទិកមិនមានប្រយោជន៍សំរាប់ព្យាបាលជំងឺមិនឆ្លងឡើយ។**

ឧទាហរណ៍នៃជំងឺមិនឆ្លង

| ជំងឺដែលបង្កឡើងដោយការសឹករិចរិលនៃសរីរាង្គក្នុងខ្លួន ឬការមានដំណើរការមិនធម្មតានៃសរីរាង្គក្នុងខ្លួន ៖ | ជំងឺដែលបង្កដោយមជ្ឈដ្ឋានខាងក្រៅដែលធ្វើឲ្យមានគ្រោះថ្នាក់ ឬមានបញ្ហាដល់សរីរាង្គ ៖ | ជំងឺដែលបង្កដោយការខ្វះសារធាតុផ្សេងៗដែលរាងកាយត្រូវការ ៖ |
|---|---|---|
| • ជំងឺរលាកសន្លាក់<br>• ជំងឺគាំងបេះដូង<br>• ជំងឺឆ្កួតជ្រូក<br>• ការដាច់សរសៃឈាមខួរក្បាល (ស្ត្រូក)<br>• ជំងឺប្រកាំង<br>• ជំងឺភ្នែកឡើងបាយ<br>• ជំងឺមហារីក | • អាល់ឡែហ្ស៊ី<br>• ជំងឺហឺត<br>• ការពុលផ្សេងៗ<br>• ពស់ចឹក<br>• ការក្អកដោយសារការជក់បារី<br>• ជំងឺដំបៅក្រពះ<br>• ការញៀនស្រា | • ការខ្វះអាហាររូបត្ថម្ភ<br>• ភាពស្លេកស្លាំង<br>• ការមានពងបែកនៅស្បែក<br>• ជំងឺខ្វាក់មាន់ និងជំងឺភ្នែកស្ងួត<br>• ជំងឺពកក និងជំងឺខ្សោយប្រាជ្ញា<br>• ជំងឺក្រិនថ្លើម |

| ជំងឺដែលកើតមានពីកំណើត | ជំងឺដែលចាប់ពីផ្លូវចិត្ត (ជំងឺផ្លូវចិត្ត) |
|---|---|
| • មាត់ឆែប<br>• ភ្នែកស្រឡៀវ ឬភ្នែកកែក<br>• ជំងឺខូចទ្រង់ទ្រាយផ្សេងៗ<br>• ជំងឺឆ្កួតជ្រូក<br>• កុមារក្រិន<br>• ការមានខ្នៅពីកំណើត | • ការខ្លាចនូវអ្វីដែលមិនពិត (ជំងឺផ្លូវចិត្ត)<br>• ភាពច្រាលច្រួល បារម្ភណ៍ក្នុងចិត្ត (ការថប់អារម្មណ៍)<br>• ការមានជំនឿលើការដាក់បណ្តាសា (អាប ធ្មប់)<br>• ការភ័យខ្លាចដែលមិនអាចគ្រប់គ្រងបាន (ការរំជួលចិត្តខ្លាំង) |

## ជំងឺឆ្លង

ជំងឺឆ្លង បណ្តាលមកពីបាក់តេរី និងមេរោគផ្សេងៗទៀតដែលធ្វើឲ្យមានគ្រោះថ្នាក់ដល់រាងកាយ។ វាអាចចម្លងតាមវិធីជាច្រើនយ៉ាង។ ខាងក្រោមនេះគឺជាប្រភេទមេរោគសំខាន់ៗមួយចំនួនដែលបណ្តាលឲ្យមានការបង្ករោគ និងឧទាហរណ៍នៃជំងឺមួយចំនួនដែលបង្កឡើងដោយមេរោគទាំងនោះ។

## ឧទាហរណ៍នៃជំងឺឆ្លង

| មេរោគដែលបង្កឲ្យមានជំងឺ | ឈ្មោះជំងឺ | វិធីដែលមេរោគឆ្លង ឬចូលក្នុងរាងកាយ | ថ្នាំសំខាន់ៗ |
|---|---|---|---|
| បាក់តេរី (មីក្រុបឬមេរោគ) | របេង | តាមខ្យល់ (ការក្អក) | ថ្នាំអង់ទីប៊ីយូទិកផ្សេងៗគ្នាប្រើសម្រាប់ការបង្ករោគផ្សេងៗគ្នា |
| | តេតាណូស | របួសកខ្វក់ | |
| | រាក | ដៃនិងទឹកមិនស្អាត សត្វរុយ | |
| | រលាកសួត (ប្រភេទខ្លះ) | តាមខ្យល់ (ការក្អក) | |
| | ប្រមេះទឹកបាយ ក្លាមីឌីយ៉ា និងស្វាយ | តាមការរួមភេទ | |
| | ឈឺត្រចៀក | ជំងឺផ្ដាសាយ | |
| | ដំបៅដែលមានការបង្ករោគ | ប៉ះពាល់វត្ថុកខ្វក់ | |
| | ដំបៅមានខ្ទុះ | ការប៉ះពាល់ផ្ទាល់ | |
| វីរុស (មេរោគតូចជាងបាក់តេរី) | ផ្ដាសាយ កញ្រ្ជឹល សាឡាទែន អ៊ុតស្វាយ ទារកខ្វិន ជំងឺរាកដែលបង្កដោយវីរុស | ឆ្លងពីអ្នកជំងឺ តាមខ្យល់ តាមការក្អក និងតាមសត្វរុយ។ល។ | ថ្នាំអាស្ពីរីននិងថ្នាំបំបាត់ការឈឺចាប់ផ្សេងទៀត (គ្មានថ្នាំដែលអាចប្រឆាំងនឹងវីរុសដោយមានប្រសិទ្ធភាពនោះទេ។ ថ្នាំ អង់ទីប៊ីយ៉ូទិក ក៏មិនអាចជួយបានដែរ)។ ការចាក់ថ្នាំបង្ការ អាចជួយបង្ការការបង្ករោគមួយចំនួនដោយវីរុស។ |
| | ជំងឺឆ្កែឆ្កួត | សត្វខាំ | |
| | ឬស | ការស្ទាប ឬការប៉ះពាល់ | |
| មេរោគផ្សិត | ស្រែង ទឹកស៊ីជើង រមាស់ក្រលៀន | តាមការប៉ះពាល់ ឬតាមសំលៀកបំពាក់ | ថ្នាំលាប អង់ដេស៊ីលេនីក បង់ហ្សូអ៊ីក អាស៊ីតសាលីស៊ីលិក គ្រីសេអូហ្វុលវីន។ |
| ពពួកប៉ារ៉ាស៊ីតក្នុងខ្លួន (ពពួកសត្វល្អិតបង្កគ្រោះថ្នាក់ក្នុងរាងកាយ) | នៅក្នុងពោះវៀនៈព្រូន អាមីប(រាកមូល) | ពីលាមកទៅមាត់ ការខ្វះអនាម័យ | ថ្នាំផ្សេងៗគ្នា |
| | នៅក្នុងឈាម : ជំងឺគ្រុនចាញ់ | មូសខាំ | ក្លរ៉ូគីន(ឬថ្នាំគ្រុនចាញ់ផ្សេងទៀត) |
| ពពួកប៉ារ៉ាស៊ីតខាងក្រៅខ្លួន (ពពួកសត្វល្អិតបង្កគ្រោះថ្នាក់នៅលើរាងកាយ) | ចៃ ចៃសាច់ សង្កើច និងសត្វល្អិតផ្សេងៗទៀត | ដោយប៉ះពាល់អ្នកជំងឺ ឬសំលៀក បំពាក់អ្នកជំងឺ | ថ្នាំសំលាប់សត្វល្អិត ថ្នាំលាបរមាស់ |

បាក់តេរី ក៏ដូចមេរោគផ្សេងទៀតដែលបង្កឲ្យកើតជំងឺដែរ វាមានទំហំតូចៗដែលយើងមិនអាចមើលឃើញនឹងភ្នែកទទេរ ដោយមិនប្រើមីក្រូស្កុបនោះឡើយ។ មីក្រូស្កុបគឺជាឧបករណ៍សំរាប់ពង្រីកវត្ថុតូចៗឲ្យមើលឃើញធំបាន។ វីរុសគឺកាន់តែមានទំហំតូចជាងបាក់តេរីទៅទៀត។



ថ្នាំអង់ទីប៊ីយ៉ូទិក (ប៉េនីស៊ីលីន តេត្រាស៊ីគ្លីន ។ល។) គឺជាថ្នាំព្យាបាលជំងឺមួយចំនួនដែលបណ្ដាលមកពីបាក់តេរី។ **ថ្នាំអង់ទីប៊ីយ៉ូទិកគ្មានប្រសិទ្ធិភាពទៅលើជំងឺដែលបង្កដោយវីរុសភាគច្រើនទេ** ដូចជា ជំងឺគ្រុនផ្ដាសាយ សាឡាទែន កញ្រ្ជឹល អ៊ុតស្វាយ។ល។ **មិនប្រើថ្នាំអង់ទីប៊ីយ៉ូទិកដើម្បីព្យាបាលការបង្ករោគដោយវីរុសទេ។** វានឹងមិនអាចជួយបានទេ ហើយវាអាចធ្វើឲ្យមានគ្រោះថ្នាក់ទៀតផង។ (មើលអង់ទីប៊ីយ៉ូទិក ទំ.៥៥)។

# ជំងឺដែលពិបាកញែកឲ្យដាច់ពីគ្នា

ជួនកាលជំងឺដែលបណ្ដាលមកពីមូលហេតុផ្សេងៗគ្នា ហើយត្រូវការការព្យាបាលខុសៗគ្នា អាចធ្វើឲ្យមានបញ្ហាដែលមានលក្ខណៈស្រដៀងគ្នា។ ឧទាហរណ៍ ៖

១. **កុមារម្នាក់ដែលចេះតែចុះស្គម និងល្វិតល្វែទៅៗ ខណៈពេលដែលពោះរបស់វាចេះតែហើមធំឡើងៗ នោះអាចបណ្ដាលមកពីមូលហេតុណាមួយ (ឬច្រើន) ដូចខាងក្រោម ៖**



- ជំងឺកង្វះអាហារូបត្ថម្ភ (ទំ.១១២)
- មានព្រូនមូលជាច្រើននៅក្នុងខ្លួន (ទំ.១៤០) (ជាទូទៅកើតមានព្រមគ្នាជាមួយនឹងជំងឺកង្វះអាហារូបត្ថម្ភ)
- ជំងឺរបេងដំណាក់កាលធ្ងន់ធ្ងរ (ទំ.១៧៩)
- ជំងឺរលាកផ្លូវនោមភ្នំរ៉ៃធ្ងន់ធ្ងរ (ទំ.២៣៤)
- ជំងឺថ្លើម ឬអណ្ដើក
- ជំងឺមហារីកឈាម
- ជំងឺរាគរុំរ៉ៃ

២. មនុស្សចាស់ដែលមានដំបៅ ដែលរីកធំបន្តិចម្ដងៗ នៅលើកជើង អាចបណ្ដាលមកពី ៖



- ចរន្តឈាមរត់មិនល្អ ដោយសារសរសៃវ៉ែនរីក ឬមូលហេតុផ្សេងៗទៀត។(ទំ.២១៣)
- ជំងឺទឹកនោមផ្អែម (ទំ.១២៧)
- ជំងឺរលាកឆ្អឹង
- ជំងឺឃ្លង់ (ទំ.១៩១)
- ជំងឺរបេងស្បែក(ទំ.២១២)
- ជំងឺស្វាយធ្ងន់ធ្ងរ (ទំ.២៣៧)

ការព្យាបាលដោយប្រើថ្នាំពេទ្យសំរាប់ជំងឺនីមួយៗខាងលើ គឺមានលក្ខណៈខុសគ្នា។ ដូច្នេះ ដើម្បីព្យាបាលជំងឺទាំងនេះឲ្យបានត្រឹមត្រូវ គេចាំបាច់ត្រូវញែកប្រភេទជំងឺទាំងនេះឲ្យដាច់ពីគ្នា។

មានជំងឺជាច្រើនមានលក្ខណៈស្រដៀងគ្នាយ៉ាងខ្លាំងនៅដំណាក់កាលដំបូង។ ប៉ុន្តែ បើអ្នកចេះសាកសួរអ្នកជំងឺឲ្យបានត្រឹមត្រូវ និងដឹងច្បាស់ថាត្រូវរកមើលអ្វី នោះជាញឹកញាប់អ្នកនឹងអាចដឹងបាននូវព័ត៌មាន និងអាចរកឃើញរោគសញ្ញាពិតប្រាកដ ដែលជួយប្រាប់អ្នកអំពីប្រភេទជំងឺរបស់មនុស្សម្នាក់ជាមិនខាន។

សៀវភៅនេះមានពិពណ៌នាអំពីប្រវត្តិនិងរោគសញ្ញាជាក់លាក់នៃជំងឺជាច្រើន។ ប៉ុន្តែសូមប្រយ័ត្ន!!! មានជំងឺច្រើនមិនបង្ហាញរោគសញ្ញាដូចដែលបានរៀបរាប់នោះឡើយ ហើយជួនកាលក៏មានរោគសញ្ញាដែលនាំឲ្យមានការច្រឡំគ្នាដែរ។ **ចំពោះករណីដែលពិបាក ការស្វែងរកជំនួយពីបុគ្គលិកសុខាភិបាលដែលមានជំនាញ ឬវេជ្ជបណ្ឌិត គឺជាការចាំបាច់។** មានពេលខ្លះ ការធ្វើតេស្ដ៍ ឬការធ្វើវិភាគផ្សេងៗគឺជាការចាំបាច់។

**ធ្វើការងារតែនៅក្នុងព្រំដែនកំណត់របស់អ្នក។ នៅក្នុងការប្រើសៀវភៅនេះ ចូរចងចាំថា អ្នកអាចធ្វើខុសបានយ៉ាងងាយ។ កុំតាំងខ្លួនថាអ្នកចេះឲ្យសោះ ចំពោះកិច្ចការណាដែលអ្នកមិនចេះ។ ប្រសិនបើអ្នកមិនប្រាកដថាជាជំងឺអ្វី ហើយមិនដឹងថាត្រូវព្យាបាលដោយរបៀបណា ឬប្រសិនបើជំងឺនោះមានសភាពធ្ងន់ធ្ងរ ត្រូវស្វែងរកជំនួយពីគ្រូពេទ្យ។**

# ជំងឺដែលតែងតែមានការយល់ច្រឡំ ឬមានឈ្មោះដូចគ្នា

មានឈ្មោះជំងឺជាច្រើនដែលគេនិយមប្រើជាយូរមកហើយ តាំងពីមុនពេលដែលគេបានរកឃើញប្រភេទមេរោគ ឬបាក់តេរី ឬថ្នាំពេទ្យដែលអាចព្យាបាលជំងឺទាំងនោះទៅទៀត។ ជាញឹកញាប់ មានជំងឺខុសៗគ្នាជាច្រើន ដែលមានរោគសញ្ញាស្ទើរតែដូចគ្នា ដូចជា "ជំងឺគ្រុនក្ដៅ" ឬ "ការឈឺចាប់មួយចំហៀងខ្លួន" ត្រូវបានគេឲ្យឈ្មោះតែមួយ។ នៅតាមតំបន់ជាច្រើននៅក្នុងពិភពលោក នៅប្រើឈ្មោះជំងឺទាំងនេះនៅឡើយ។ វេជ្ជបណ្ឌិតដែលបានទទួលការបណ្ដុះបណ្ដាលនៅទីក្រុង តែងតែមិនស្គាល់ និងមិនដែលប្រើឈ្មោះជំងឺទាំងនោះទេ។ ដោយហេតុនេះហើយ បានជា នៅពេលខ្លះប្រជាជនយល់ថា ពួកគេមាន "ជំងឺដែលវេជ្ជបណ្ឌិតមិនអាចព្យាបាល"។ ដូច្នេះហើយបានជាពួកគេព្យាបាលជំងឺទាំងនេះដោយប្រើរុក្ខជាតិ ឬវិធីព្យាបាលបែបបុរាណវិញ។

តាមពិត ភាគច្រើននៃជំងឺតាមតំបន់ទាំងនេះ ដូចគ្នានឹងជំងឺដែលវិទ្យាសាស្ត្រវេជ្ជសាស្ត្របានរកឃើញនោះដែរ ប៉ុន្តែគ្រាន់តែមានឈ្មោះខុសគ្នាតែប៉ុណ្ណោះ។

**ចំពោះជំងឺជាច្រើន ការព្យាបាលតាមបែបបុរាណអាចមានប្រសិទ្ធិភាពល្អ។ ប៉ុន្តែចំពោះជំងឺខ្លះទៀត ការព្យាបាលដោយប្រើថ្នាំពេទ្យ មានប្រសិទ្ធិភាពជាង និងអាចជួយសង្គ្រោះជីវិតទៀតផង។** នេះគឺជាការពិត សំរាប់ជំងឺដែលមានគ្រោះថ្នាក់ ដូចជា ៖ ជំងឺរលាកសួត គ្រុនពោះវៀន របេង ឬការបង្ករោគផ្សេងៗក្រោយពេលសម្រាលកូន។ល។

ដើម្បីយល់ច្បាស់ថាតើជំងឺណាត្រូវការការព្យាបាលដោយប្រើថ្នាំពេទ្យ និងដើម្បីសម្រេចចិត្តថាត្រូវប្រើថ្នាំអ្វីនោះ គេចាំបាច់ត្រូវ**ស្គាល់ឈ្មោះជំងឺ ដែលបុគ្គលិកសុខាភិបាលដែលបានទទួលការបណ្ដុះបណ្ដាល និយមប្រើ និងឈ្មោះជំងឺដែលមាននៅក្នុងសៀវភៅនេះ។**

**ប្រសិនបើអ្នកមិនអាចរកឃើញជំងឺដែលអ្នកចង់ដឹង នៅក្នុងសៀវភៅនេះទេ អ្នកអាចរកវាតាមឈ្មោះផ្សេងមួយទៀត ឬរកនៅក្នុងជំពូកដែលនិយាយអំពីប្រភេទជំងឺដូចគ្នា។ សូមប្រើមាតិកាអត្ថបទ និងលិបិក្រម។**

ប្រសិនបើអ្នកមិនប្រាកដថាជាជំងឺអ្វីនោះ ជាពិសេសប្រសិនបើវាជាជំងឺធ្ងន់ធ្ងរ ចូរប្រញាប់ស្វែងរកជំនួយពីគ្រូពេទ្យជាបន្ទាន់។

**អត្ថបទចាប់ពីទំព័រ២២ ដល់២៥ មិនត្រូវបានបញ្ចូលក្នុងការបោះពុម្ពជាភាសាខ្មែរនេះទេ។**

# ការយល់ច្រឡំអំពីជំងឺផ្សេងៗដែលបណ្ដាលឲ្យមានគ្រុនក្ដៅ



បើនិយាយឲ្យត្រឹមត្រូវ គ្រុនក្ដៅគឺជា**ការកើនឡើងនៃសីតុណ្ហភាពរាងកាយខ្ពស់ជាងធម្មតា។** ប៉ុន្តែ ជំងឺធ្ងន់មួយចំនួនដែលបណ្ដាលឲ្យមានសីតុណ្ហភាពខ្ពស់ ត្រូវបានគេហៅថា គ្រុនក្ដៅ។

ដើម្បីបង្ការ ឬព្យាបាលជំងឺទាំងនេះឲ្យបានជោគជ័យ គេចាំបាច់ត្រូវស្គាល់អំពីលក្ខណៈខុសគ្នានៃជំងឺនីមួយៗ។

ខាងក្រោមនេះ គឺជាជំងឺស្រួចស្រាវមួយចំនួន ដែលគ្រុនក្ដៅគឺជារោគសញ្ញាយ៉ាងសំខាន់របស់វា។ គំនូរនេះបង្ហាញអំពី**លក្ខណៈនៃគ្រុនក្ដៅ** (ការកើនឡើងនិងការថយចុះនៃសីតុណ្ហភាព) តាមប្រភេទជំងឺនីមួយៗ ៖

**ជំងឺគ្រុនចាញ់** (មើលទំ.១៨៦)

ជំងឺនេះ ចាប់ផ្ដើមឡើងដោយមានការអស់កម្លាំង រងាញាក់ និងគ្រុនក្ដៅ។ អាការៈគ្រុនក្ដៅអាចកើតមាន និងបាត់ទៅវិញ ក្នុងរយៈពេលពីរបីថ្ងៃ ដោយមានរងាញាក់នៅពេលសីតុណ្ហភាពឡើង ហើយមានបែកញើសនៅពេលសីតុណ្ហភាពថយចុះ។ បន្ទាប់មក អាចមានគ្រុនក្ដៅ ក្នុងរយៈពេលពីរបីម៉ោង រៀងរាល់ពីរ ឬបីថ្ងៃម្ដង។ នៅថ្ងៃផ្សេងទៀត អ្នកជំងឺហាក់ដូចជាមានសភាពធូរស្រាល។




**ជំងឺគ្រុនពោះវៀន** (មើលទំ.១៨៨)

ជំងឺនេះ ចាប់ផ្ដើមឡើងដូចជំងឺផ្ដាសាយដែរ។ សីតុណ្ហភាពឡើងបន្តិចៗជារៀងរាល់ថ្ងៃ។ ជីពចរយឺត។ ជួនកាលមានរាក និងខ្សោះជាតិទឹក។ អាការៈញ័រខ្លួន ឬរវើរវាយ (គំនិតរវើរវាយ) អ្នកជំងឺមានសភាពធ្ងន់ធ្ងរ។




**ជំងឺទីហ្វូស** (មើលទំ.១៩០)

ស្រដៀងនិងជំងឺគ្រុនពោះវៀនដែរ។ មានកន្ទួល ដូចក្នុងជំងឺកញ្ជ្រឹលដែរ ដោយមានស្នាមជាំតូចៗជាច្រើន នៅលើទ្រូងនិងពោះ។




**ជំងឺរលាកថ្លើម** (មើលទំ.១៧២)

អ្នកជំងឺមិនឃ្លានអាហារ។ មិនចង់បរិភោគ។ ចង់ក្អួតចង្អោរ។ ភ្នែកនិងស្បែកឡើងលឿង ទឹកនោមឡើងពណ៌ទឹកក្រូច ឬពណ៌ត្នោត លាមកមានពណ៌ស។ ជួនកាលថ្លើមរីកធំហើយឈឺ។ មានគ្រុនក្ដៅស្ទិញៗ។ អ្នកជំងឺអស់កម្លាំង។

**ជំងឺរលាកស្ងួត** (មើលទំ.១៧១)

ដកដង្ហើមញាប់។ សីតុណ្ហភាពឡើងយ៉ាងលឿន។ ក្អកមានស្លេះពណ៌បៃតង លឿង ឬលាយឈាម។ អាចមានការឈឺក្នុងទ្រូង។ អ្នកជំងឺមានសភាពធ្ងន់ធ្ងរ។

*លក្ខណៈគ្រុនក្តៅក្នុងជំងឺរលាកស្ងួត*




**ជំងឺគ្រុនរលាកសន្លាក់** (មើលទំ.៣១០)

ច្រើនកើតលើកុមារ និងក្មេងជំទង់។ ឈឺក្នុងសន្លាក់។ គ្រុនក្តៅ។ ភាគច្រើនកើតបន្ទាប់ពីមានឈឺបំពង់ក។ អាចមានការឈឺក្នុងទ្រូង និងមានការដកដង្ហើមខ្លីៗ។ ឬដៃនិងជើងមានចលនាដែលមិនអាចគ្រប់គ្រងបាន។

*លក្ខណៈគ្រុនក្តៅក្នុងជំងឺគ្រុនរលាកសន្លាក់*




**ជំងឺប្រ៊ូសែឡូស** (មើលទំ.១៨៧)

ជំងឺនេះ ចាប់ផ្តើមឡើងយឺតៗ ដោយ អស់កម្លាំង ឈឺក្បាល ឈឺឆ្អឹងឆ្អែង។ គ្រុនក្តៅ និងបែកញើស ជាពិសេសនៅពេលយប់។ គ្រុនក្តៅបានបាត់ទៅវិញ ក្នុងរយៈពេលពីរបីថ្ងៃ បន្ទាប់មក ក៏ត្រឡប់មកវិញ។ បញ្ហានេះ អាចកើតមានរាប់ខែ ឬរាប់ឆ្នាំ។

*លក្ខណៈគ្រុនក្តៅក្នុងជំងឺប្រូសេឡូស*




**ជំងឺគ្រុនក្តៅក្រោយសម្រាលកូន** (មើលទំ.២៧៦)

ចាប់ផ្តើមឡើងមួយថ្ងៃ ឬច្រើនថ្ងៃបន្ទាប់ពីសម្រាលកូន។ ចាប់ផ្តើមដោយមានគ្រុនក្តៅបន្តិចបន្តួច ហើយច្រើនតែ ឡើងខ្ពស់នៅពេលក្រោយ។ មានធ្លាក់ទឹករំអិលដែល មានក្លិនស្អុយ តាមទ្វារមាស។ មានការឈឺចាប់ និងជួនកាលមានធ្លាក់ឈាម។

*លក្ខណៈគ្រុនក្តៅក្នុងជំងឺគ្រុនក្តៅក្រោយពេលសម្រាលកូន*




**គ្រប់ជំងឺទាំងនេះសុទ្ធតែអាចមានគ្រោះថ្នាក់។** បន្ថែមទៅនឹងជំងឺដែលបានបង្ហាញខាងលើ នៅមានជំងឺជាច្រើនទៀត ដែលអាចមានរោគសញ្ញានិងគ្រុនក្តៅស្រដៀងគ្នានេះ។ ឧទាហរណ៍ដូចជា ៖ ការមានគ្រុនក្តៅលើសពីមួយខែ ឬមានបែកញើសនៅពេលយប់ អាចបណ្តាលមកពីមេរោគអេដស៍/ជំងឺអេដស៍ (ទំ.៣៩៩)។ ដូច្នេះ ប្រសិនបើអាចធ្វើបាន ត្រូវស្វែងរកជំនួយពីគ្រូពេទ្យជាបន្ទាន់។